ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ៨ លេខ ៨៦ សប្តាហ៍ទី ៣ ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨

រាជកិច្ច

ផ្សាយដោយ

ទីស្តីការគណៈរដ្ឋមន្ត្រី

តម្លៃ

១ ច្បាប់	៥.០០០ រៀល
១ ខែ	៤០.០០០ រៀល
៣ ខែ	១២០.០០០ រៀល
៦ ខែ	២៤០.០០០ រៀល
១២ ខែ	៤៨០.០០០ រៀល

(ត្រូវបង់ថ្លៃជាមុន)

មាតិកា

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរ ប្រកាស

មាតិកា

I.ខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៤-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២០៣ ស្តីពីការតែងតាំងទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចំនួន ០២ រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ ៨៣៨២

០៤-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២០៤ ស្តីពីការប្រោសព្រះរាជទានចំពោះសពឯកឧត្តម នាយឧត្តមសេនីយ៍ **ស៊ិន ពិនសេន** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍ ជាកិច្ចបច្ឆាមរណៈ ៨៣៨៣

០៤-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២០៥ ស្តីពីការតែងតាំងឯកឧត្តម **មាស ម៉ូ** ជាអនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៣៨៤

០៤-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២០៦ ស្តីពីការតែងតាំងមន្ត្រីរាជការចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៨៣៨៥

០៤-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២០៧ ស្តីពីការតែងតាំងមន្ត្រីរាជការចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៨៣៨៦

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២០៩ ស្តីពីការតែងតាំងជាទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភានីតិកាលទី ៤ ចំនួន ៣០ រូប ៨៣៨៧

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១០ ស្តីពីការតែងតាំងឯកឧត្តម **សំរិទ្ធ សាម៉ន** ជាឧកញ៉ា ៨៣៨៩

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១១ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូបជាសមាជិក និងជាសមាជិកបំរុងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ៨៣៩០

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១២ ស្តីពីការប្រោសព្រះរាជទានគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងអស់លោក ចំនួន ១៥ រូប ៨៣៩១

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១៣ ស្តីពីការតែងតាំងមេធាវីរាជរដ្ឋាភិបាលចំនួន ០៤ រូប ៨៣៩២

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១៤ ស្តីពីការតែងតាំងឯកឧត្តម **ជា សំអាង** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៨៣៩៣

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១៥ ស្តីពីការប្រគល់ភារកិច្ចជូនឯកឧត្តម ខៀវ មាន់រិត អោយបំពេញមុខងារជាអគ្គលេខាធិការរងនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានឋានៈស្មើអគ្គនាយក ៨៣៩៤

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១៨ ស្តីពីការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម និងអស់លោក ចំនួន ៣០ រូប ៨៣៩៥

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២១៩ ស្តីពីការតម្លើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោជូនឧត្តមសេនីយ៍ត្រី គង់ សារឹម នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ៨៣៩៧

០៦-១១-២០០៨ -ព្រះរាជក្រឹត្យ នស/រកត/១១០៨/១២២០ ស្តីពីការតម្លើងឋានន្តរស័ក្តិ នាយទាហាននៃកងយោធពលខេមរភូមិន្ទ ចំនួន ០៥ រូប ៨៣៩៨

II-រាជរដ្ឋាភិបាល

១-អនុក្រឹត្យ

១៧-១១-២០០៨-អនុក្រឹត្យលេខ ១៩០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨៣៩៩

១៧-១១-២០០៨-អនុក្រឹត្យលេខ ១៩១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨៤០១

១៧-១១-២០០៨-អនុក្រឹត្យលេខ ១៩២ អនក្រ.បក ស្តីពីការផ្តល់ឥណទានថវិកាបន្ថែមសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ៨៤០៣

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៥

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១២ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៨៤០៦

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៧

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤០៨

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៥ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៤០៩

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៨៤១០

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៧ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៨៤១២

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៨ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៨៤១៤

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២១៩ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨៤១៨

១៧-១១-២០០៨-អនុក្រឹត្យលេខ ១២២០ អនក្រ.តត ស្តីពីការសំរួលភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨៤១៩

១៧-១១-២០០៨ -អនុក្រឹត្យលេខ ១២២១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៤២១
១៧-១១-២០០៨ -អនុក្រឹត្យលេខ ១២២២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៨៤២២
១៨-១១-២០០៨ -អនុក្រឹត្យលេខ ១២២៣ អនក្រ.តត ស្តីពីការតែងតាំង និងការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៤២៣

២.សេចក្តីសំរេច

១៧-១១-២០០៨ -សេចក្តីសំរេចលេខ ២៨ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រី នៃបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ៨៤២៥
១៨-១១-២០០៨ -សេចក្តីសំរេចលេខ ២៩ សសរ ស្តីពីការផ្លាស់ប្តូរសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលជាតិគ្រប់គ្រងគំរោងជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ៨៤២៨

III.ការងារបណ្តាក្រសួង

១.នីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៧-១១-២០០៨ -ប្រកាសលេខ ១២៦៣ សហវ.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់បណ្តាការិយាល័យនៃនាយកដ្ឋានផែនការបច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ៨៤៣០
០៧-១១-២០០៨ -ប្រកាសលេខ ១២៦៤ សហវ.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់បណ្តាការិយាល័យនៃនាយកដ្ឋានកិច្ចការច្បាប់ និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ៨៤៣៤
០៧-១១-២០០៨ -ប្រកាសលេខ ១២៦៥ សហវ.ប្រក ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់បណ្តាការិយាល័យនៃនាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ៨៤៣៨

២.នីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៣៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រូនស៍ ឋាស** ៨៤៤២
០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ខម្បានី មេគាយើរ** ៨៤៤៤
០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ី & ម៉ី អ៊ិនធើណេសិនណល** ៨៤៤៦
០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **គ្រីអេធីវ អេនធើធេនមេន ខូ អិលធីឌី** ៨៤៤៨
០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៤២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រ៊ីវ ឃែពីថល អ៊ិនវេសមេន ខូ អិលធីឌី** ៨៤៥០

០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៤៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាត្លង់ទិក វើលដ៍** ៨៤៥២

០៧-៨-២០០៧ -លិខិតបញ្ជាក់លេខ ៣០៤៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេអិមខេមទៀត អ៊ីមផត អិចផត** ៨៤៥៤

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២០៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវុឌ្ឍា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងទីប្រឹក្សាក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ខួន នៅ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២- ឯកឧត្តម **ពិត ជាំ** មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរក.០៩១១.១២៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៣៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

សពឯកឧត្តម នាយឧត្តមសេនីយ៍ **ស៊ិន ពិនសេន**

នូវ

គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេរីវឌ្ឍន៍**

ជាកិច្ចបច្ឆាមរណៈ

៣រល.០៩១១.១២២៣

ព្រះហស្តលេខា និងព្រះរាជលញ្ជករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ: ១១៣៧ ច.ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានតែងតាំងឯកឧត្តម មាស ប៉ូ ជាអនុរដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៩ល. ០៧១១. ១២២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១៣៣៧ ច.ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២០៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមន្ត្រីរាជការ ចំនួន ០៣ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **ទី សារ៉ាន**

២-លោកជំទាវ **លឹម មុំ**

៣-ឯកឧត្តម **ឈាង ប៊ុនរិទ្ធ** ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ១១៣០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រជ.០៧១១.១២២៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្តម **សេង សារុន**

២-ឯកឧត្តម **ឃួន ទិទិត្រ** ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យ បានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៧១១.១២២៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុន ចិនឆេង

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២០៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0៧0៤/00១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២00៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី៤ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២00៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤ ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ជាទីប្រឹក្សា និងជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤ :

ក-ទីប្រឹក្សា :

១- ឯកឧត្តម **ចាយ បូរិន** មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន
២- លោកជំទាវ **ឡុង សាខន** មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន
៣-ឯកឧត្តម **ខែត សំអុន** មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន
៤-ឯកឧត្តម **ឆា ច័ន្ទសីដា** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៥-ឯកឧត្តម **ជ្រួន ថេរីថាត** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៦-ឯកឧត្តម **ហ៊ី ស៊ិនគីរម្យ** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៧-ឯកឧត្តម **យិន ប៊ុនណាង** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៨-ឯកឧត្តម **ម៉ឺន សុផល** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
៩-ឯកឧត្តម **ព្រហ្ម ផល** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន
១០-ឯកឧត្តម **ស៊ឹម ស៊ុនធីម** មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

១១-ឯកឧត្តម ពេជ្រ សំណាង មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១២-ឯកឧត្តម ម៉េង ម៉ាន់ឌី មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៣-ឯកឧត្តម ថន សារ៉ាត មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៤-ឯកឧត្តម លឹម ហាបឌី មានឋានៈស្មើ រដ្ឋលេខាធិការ

១៥-ឯកឧត្តម តាំង ឈុនឌី មានឋានៈស្មើ រដ្ឋលេខាធិការ

១៦-ឯកឧត្តម តាន់ យឹមសាយ មានឋានៈស្មើ រដ្ឋលេខាធិការ

១៧-ឯកឧត្តម ហួង ម៉ុងហេង មានឋានៈស្មើ រដ្ឋលេខាធិការ

១៨-ឯកឧត្តម ហ៊ាង សុជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

១៩-ឯកឧត្តម សុត គឹមសាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២០-ឯកឧត្តម មិត សាផាណា មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២១-ឯកឧត្តម សុខ ចណ្ណនី មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២២-ឯកឧត្តម ស្វន ស៊ីថុន មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៣-ឯកឧត្តម ហួង-សេងហួរ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៤-ឯកឧត្តម ព្រហ្ម ធីរៈ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៥-ឯកឧត្តម សន សិទ្ធ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

២៦-ឯកឧត្តម អ៊ឹង អៀច មានឋានៈស្មើ អនុរដ្ឋលេខាធិការ

២៧-ឯកឧត្តម តាំង យូហួង មានឋានៈស្មើ អនុរដ្ឋលេខាធិការ

ខ-ជំនួយការៈ

១-ឯកឧត្តម លី ឡេង មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

២-ឯកឧត្តម ចិន នី មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

៣-លោកជំទាវ ចាន់ បូផាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន

មាត្រា ២ : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤ល. ០៧១១. ៦២២៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ:១១៣៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០០៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា)

តែងតាំង

លោក **ស៊ីវឌ្ឍ សាម៉ន**

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៩៧.០៩១១.១២២៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៩៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/៦២១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

១- ឯកឧត្តម **សួន វិសាល** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ

២- ឯកឧត្តម **ព្រហ្ម វិចិត្ររង្សី** ជាសមាជិកបំរុងក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ អគ្គនាយក

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤.០៩១១.៦២៣០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ: ១៤៣ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិន្តា

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២១២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជ្យរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនចំពោះ :

១- ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ៅ ប៊ុនណារិន
២- ឯកឧត្តម សេង យូអ៊ាន់

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ :

១- ឧត្តមសេនីយ៍ទោ អ៊ុន ឈុន
២- ឧត្តមសេនីយ៍ទោ ជា ចន្ថា
៣- ឧត្តមសេនីយ៍ទោ ហ៊ូ សាគុណ
៤- ឧត្តមសេនីយ៍ទោ រស់ នីមសារុន
៥- ឧត្តមសេនីយ៍ត្រី ហ៊ាន សារឿន
៦- ឧត្តមសេនីយ៍ត្រី កុសល តិរមៀ
៧- ឧត្តមសេនីយ៍ត្រី ប៊ុក សុខន
៨- ឧត្តមសេនីយ៍ត្រី ហែម ថេង
៩- ឧត្តមសេនីយ៍ត្រី ធីម សុផា
១០- ឧត្តមសេនីយ៍ត្រី ច័ន្ទ សុវណ្ណ
១១- វរសេនីយ៍ឯក ញៀម សុខន
១២- វរសេនីយ៍ឯក ថី សុខុម
១៣- លោក អឿម សុខុន

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៥១១.១២៣១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ:១១៤៧/ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនពេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងមេធាវីរាជរដ្ឋាភិបាលដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម គី តិច មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម ឡុង នរិន្ទ មានឋានៈស្មើ រដ្ឋលេខាធិការ

៣- ឯកឧត្តម ឡុង ដារ៉ា មានឋានៈស្មើ អនុរដ្ឋលេខាធិការ

៤- ឯកឧត្តម ឈិត បូរ៉ាធុច មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣ល.០៧១១.១២៣២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៥១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរាជរដ្ឋាភិបាល

ប៊ិន ឈិន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង ឯកឧត្តម **ជា សំអាង** ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧.០៩១១.១២៣៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ ១១៥៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០០៨
[illegible] អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍនវិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម ខា មានិត អោយបំពេញមុខងារជាអគ្គលេខាធិការរងនៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍ វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានឋានៈស្មើអគ្គនាយក ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣១៧.០៧១១.១២៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខ: ១១៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២១៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ដូច

ក_គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០២ រូប :

១	ឯកឧត្តម	នឹម	ជុត	២	លោកឧកញ៉ា	ភូ	ពុយ

ខ_គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ ចំនួន ០៦ រូប :

១	ឯកឧត្តម	នេត	សារឿន	៤	ឯកឧត្តម	ឃុន	ឈុន្នី
២	ឯកឧត្តម	អ៊ុក	គឹមឈេង	៥	ឯកឧត្តម	សួស	អប្សារី
៣	លោកជំទាវ	គឹម	ចាន់ឡូ	៦	ឧត្តមសេនីយ៍ត្រី	ឃុន	សំបូរ

គ_គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា ចំនួន ២២ រូប :

១	ឯកឧត្តម	ទូច	វិសាលសុខ	១២	លោកវរសេនីយ៍ឯក	ឈឿប	សុខុម
២	លោកជំទាវ	ស៊ឹម	ម៉ារី	១៣	លោកវរសេនីយ៍ឯក	រ៉េន	សុផុន
៣	ឯកឧត្តម	ប្រាក់	ឡឿន	១៤	លោកវរសេនីយ៍ឯក	ចាម	ប៊ុនសេង
៤	ឯកឧត្តម	ស៊ុយ	ប៊ុនហេង	១៥	លោកវរសេនីយ៍ឯក	នូ	សារ៉ិទ្ធ
៥	ឧត្តមសេនីយ៍ទោ	ម៉ក់	ជីតូ	១៦	លោកវរសេនីយ៍ឯក	អ៊ុក	គឹមសាមារ៉ៃ
៦	ឧត្តមសេនីយ៍ត្រី	ចាន់	ចាយ	១៧	លោកវរសេនីយ៍ឯក	វៃ	សុវណ្ណ
៧	ឧត្តមសេនីយ៍ត្រី	សេង	វណ្ណា	១៨	លោកវរសេនីយ៍ឯក	ជា	ជួន-

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

៨	ឧត្តមសេនីយ៍ត្រី	**ចាន់**	**តឹមសេង**	១៩	លោកវរសេនីយ៍ទោ	**វ៉ែត**	**ល្បេង**
៩	ឧត្តមសេនីយ៍ត្រី	**អ៊ីន**	**បូរ៉ា**	២០	លោក	**អ៊ុច**	**អាង**
១០	ឧត្តមសេនីយ៍ត្រី	**ម៉ៅ**	**តារា**	២១	លោក	**ជាម**	**ច័ន្ទសោភ័ណ**
១១	ឯកឧត្តម	**ជា**	**តារេ**	២២	លោក	**គឹម**	**ឡេង**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣៩ល.០៧១១.១២៣៧

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៤៩ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ម៉ានិត

ព្រះរាជក្រឹត្យ

នស/រកត/១១០៨/១២១៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូន ឧត្តមសេនីយ៍ត្រី **គង់ សាលី** អត្តលេខ ០០០២៥៥ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៧.០៨១១.១២៣៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ជិនកេន

នស/រកត/១១០៨/១២២០

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនា សម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតម្លើងឋានន្តរស័ក្តិ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ៖

ក-តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ទោ

១-ឧត្តមសេនីយ៍ត្រី **ស៊ុន សុផល** អត្តលេខ ០០១០១៩
២-ឧត្តមសេនីយ៍ត្រី **ថោង ត្រាសាន** អត្តលេខ ០០០៤១៧

ខ-តម្លើងឋានន្តរស័ក្តិថ្នាក់ឧត្តមសេនីយ៍ត្រី

១-វរសេនីយ៍ឯក **ព្រហ្ម សំអុល** អត្តលេខ ០០០៩៦៤
២-វរសេនីយ៍ឯក **នាង យឹម** អត្តលេខ ០០១១៥៩
៣-វរសេនីយ៍ឯក **គីម សេងឧន** អត្តលេខ ០០០៤១៨

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧.០៧១១.១២៣៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ២០០៨

លេខៈ ១១៤៤ ច.ល

ចំលងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៨

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨៖
- បានឃើញប្រកាសលេខ ១៤៤៨ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- បានឃើញប្រកាសលេខ ១៤៥០ សហវ.ប្រក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណាយឥណទានថវិកាផ្នែកក្នុងជំពូក គណនី អនុគណនី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨
- យោងលិខិតលេខ ២៥២៣ ព.ណ គន ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ របស់ក្រសួងពាណិជ្ជកម្ម ។
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១ : ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន: ២៥៥.០០០.០០០រៀល (ពីររយហាសិបប្រាំលានរៀលគត់) ពីជំពូក ៦២ (សេវាខាងក្រៅផ្សេងៗ) មកជំពូក ៦០ (ការទិញ) ជូនក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។

មាត្រា២ : ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបំពេញតំរូវការចំណាយជាក់ស្តែងរបស់ក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៧១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ . ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ . ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ .
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក . ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៨ អនក្រ.បក . ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០៤ អនក្រ.បក . ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១៥.៨១៣ លានរៀល (ដប់ប្រាំពាន់ប្រាំបីរយដប់បីលានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦៤ (បន្ទប់បុគ្គលិក) ជូនក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់បើករបបគោលនយោបាយជូនយោធិនពលី ពិការ មរណៈ ចំនួន ១.៧០១ នាក់ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៩៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្តល់ឥណទានថវិកាបន្ថែម

សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ . ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ . ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣៥ . ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក . ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក . ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០៤ អនក្រ.បក . ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៧ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៨
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ដោយអនុលោមទៅតាមមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានអនុញ្ញាតអោយបន្ថែម ឥណទានថវិកា ចំនួន ១៣.៧៣២ លានរៀល (ដប់បីពាន់ប្រាំពីររយសាមសិបពីរលានរៀលគត់) ទៅលើសៀវភៅថវិកា របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ។

មាត្រា២: ឥណទានថវិកាបន្ថែមដូចក្នុងមាត្រា ១ ខាងលើ ត្រូវបានបន្ថែមនៅជំពូក ៦៤ សំរាប់បើករបបគោលនយោបាយជូនយោធិន ពលី ពិការ មរណៈ ចំនួន ១.៩៣២ នាក់ ។

មាត្រា៣: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា៤: ឥណទានថវិកាបន្ថែមនេះ ត្រូវបានរដ្ឋសភាពិនិត្យអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុ នាពេលខាងមុខ កាលបើការបោះអាណត្តិបើកប្រាក់ ទូទាត់ចំណាយបើករបបគោលនយោបាយជូនយោធិនពលី ពិការ មរណៈ ត្រូវបានចប់សព្វគ្រប់ ។

មាត្រា៥: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤១១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

